# ការតម្រៀបរឿងឯកសារ ៖
# ការពិភាក្សាគ្នាទាក់ទងនឹងភស្តុតាងបានពន្យារពេលដល់ការធ្វើសក្ខីកម្មសាក្សី

***ដោយ គ្រីស្ទីន ស៊ីវេន***

***ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១***

*ប្រែសម្រួលដោយ ជា ផល្លា*

សម្រាប់ឆ្នាំ២០១១ សវនាការលើសំណុំរឿង០០២បានបញ្ចប់នៅថ្ងៃនេះ ។ សវនាការថ្ងៃនេះបញ្ចប់ទៅប្រកបដោយការពិភាក្សាយ៉ាងក្តៅគគុកទាក់ទងនឹងភស្តុតាងខ្សែភាពយន្ត ដែលបង្កឲ្យមានការរំខានដល់ការចោទសួរទៅសាក្សី ឡុង នរិន្ទ និងជនជាប់ចោទ នួន ជា ។

ទោះបីជាថ្ងៃនេះជាថ្ងៃចុងក្រោយក៏ដោយ ក៏អ្នកតាមដានតុលាការបានចូលរួមមើលដំណើរការនេះស្ទើរពេញកៅអីអង្គុយទាំងអស់ ដោយអ្នកភូមិចូលរួមនៅពេលព្រឹក និងសិស្សានុសិស្សមកចូលរួមនៅពេលរសៀល ។ ការពិភាក្សាដ៏តានតឹងនេះ បានធ្វើឲ្យអ្នកចូលរួមតាមដានយ៉ាងយកចិត្តទុកដាក់ ដែលធ្វើឲ្យសន្តិសុខយាមការពារនៅទីនោះ អាចមានពេលសម្រាកខ្លះបាន ព្រោះមិនមានសិស្សណាម្នាក់លួចដេកនៅក្នុងបន្ទប់ទេ ។

## ក្រុមមេធាវីរបស់ នួន ជា បន្តសួរ ឡុង នរិន្ទ

ចៅក្រម និល ណុន បានជម្រាបទៅគ្រប់ភាគីទាំងអស់ថា ការធ្វើសក្ខីកម្មរបស់ ឡុង នរិន្ទ ដែលសួរដោយព្រះរាជអាជ្ញាអាចនឹងបន្ត និងបញ្ចប់នៅពេលព្រឹកនេះ ។ ក្រោយមក ចៅក្រម និល ណុន បានប្រគល់វេទិកាទៅឲ្យក្រុមមេធាវីរបស់ នួន ជា ដើម្បីសួរសំណួរទៅសាក្សី ឡុង នរិន្ទ ដែលត្រូវបានរំខានកាលពីម្សិលមិញ ហើយនៅពេលព្រឹកនេះចៅក្រមបានឲ្យពេលចំនួនដប់នាទីទៅក្រុមមេធាវីរបស់ នួន ជា ដើម្បីបញ្ចប់ការសាកសួរទៅសាក្សី ។

មេធាវី ម៉ៃខល ផេសមិន របស់ នួន ជា បានចាប់ផ្តើមសួរអំពីអ្វីដែលថាក្នុងកិច្ចប្រជុំឆ្នាំ១៩៧៧ នៅក្រសួងការបរទេស អៀង សារី បាននិយាយថា គាត់មិនអនុញ្ញាតឲ្យមានការចាប់ខ្លួនកម្មាភិបាលណាមួយនៅក្នុងក្រសួងរបស់គាត់ទេពេលដែលគាត់មិននៅក្នុងប្រទេស ។ មេធាវី ផេសមិន បានសួរទៅសាក្សី ឡុង នរិន្ទ ថា «តើនរណាប្រាប់ពីរឿងនេះដល់គាត់?» ។ ឡុង នរិន្ទ បានឆ្លើយថា ពាក្យនេះត្រូវបានផ្សព្វផ្សាយក្នុងអំឡុងពេលប្រជុំនៅក្រសួង«នរណាក៏ដឹងរឿងនេះដែរ ។ កាលនោះគេមិនប្រើពាក្យ«ចាប់ខ្លួន» ទេ តែ អៀង សារី និយាយថា គ្មាននរណាត្រូវយកចេញទៅណាក្រៅទេ ពេលដែលគាត់មិននៅ» ។

ដោយសារតែសាក្សីមិនឆ្លើយចំសំណួរ មេធាវី ផេសមិន បានអានសង្ខេបនូវអ្វីដែលសាក្សីបាននិយាយពេលដែលគាត់សម្ភាសជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ មេធាវី ផេសមិន បានបញ្ជាក់ថា ឡុង នរិន្ទ បាននិយាយអំពីសហការីរបស់គាត់ម្នាក់ឈ្មោះ គាត ឈុន ដែលបានប្រាប់គាត់អំពីកិច្ចប្រជុំនេះ។

ពេលនោះ ជំនួយការសហព្រះរាជអាជ្ញា ឌុល លីសាក់ បានជំទាស់នឹងសំណួរនោះដោយបញ្ជាក់ថា មេធាវីការពារក្តី បាន“អានខុសនូវអ្វីដែលសាក្សីបាននិយាយនៅក្នុងបទសម្ភាស”។ ឌុល លីសាក់ បានបញ្ជាក់ថា មេធាវី ផេសមិន គួរតែអានពាក្យដែលសាក្សីនិយាយពិតប្រាកដទៅកាន់សាក្សី ធ្វើដូច្នេះទើបគាត់អាចដឹងពីប្រធានបទទាំងមូលទាក់ទងទៅនឹងថា នរណាដែលប្រាប់សាក្សីអំពីកិច្ចប្រជុំនៅក្រសួងការបរទេសនោះ។

មេធាវី ផេសមិន បានបន្តសួរសំណួរមួយទៀតដោយបញ្ជាក់ថា តាមរយៈកិច្ចសម្ភាសន៍មួយក្នុងឆ្នាំ២០០៧ ឡុង នរិន្ទ បាននិយាយពី គាត ឈុន ចំនួនប្រាំដង តែពេលដែលគាត់មកធ្វើសក្ខីកម្មនៅពេលនេះ គាត់មិនបាននិយាយពីឈ្មោះនេះសូម្បីតែម្តងសោះ ហើយក្រោយមកមេធាវីរូបនេះបានសួរទៅសាក្សីថា “តើលោកមានអារម្មណ៍ចង់ធ្វើសក្ខីកម្មនេះទេ?”។ ឡុង នរិន្ទ បានឆ្លើយថា “គ្មាននរណាដាក់សម្ពាធលើខ្ញុំទេ”។ ពេលសួរបន្តទាក់ទងនឹងបញ្ហានេះ ឡុង នរិន្ទ បានបដិសេធថា គ្មាននរណាមកជួបគាត់ទេក្រោយឆ្នាំ២០០៧ទាក់ទងនឹងសក្ខីកម្មនៅសាលាក្តីខ្មែរក្រហម។

នៅពេលសួរថាតើគាត់មានដឹងថា គាត ឈុន រស់ថ្ងៃធ្វើអ្វីទេ សាក្សីបានឆ្លើយថា គាត់មិនដឹងទេ ហើយគាត់មិនបានជួប គាត ឈុន យូរមកហើយ។ ក្រោយមក មេធាវី ផេសមិន បានប្រាប់ថា គាត ឈុន សព្វថ្ងៃគឺជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងជាឧបនាយករដ្ឋមន្ត្រីកម្ពុជា ហើយក្រោយមកមេធាវីបានសួរទៅសាក្សីថាមានដឹងទេថាហេតុអ្វីបានជា គាត ឈុន បដិសេធមិនចូលមកធ្វើសក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរបស់សាលាក្តីខ្មែរក្រហម។ ឌុល លីសាក់ បានងើបឡើងដើម្បីជំទាស់ តែមុននឹងគាត់និយាយ ចៅក្រម និល ណុន បានប្រាប់ទៅសាក្សីថា មិនត្រូវឆ្លើយសំណួរនេះទេ ព្រោះសំណួរនេះនៅក្រៅពីដែនកំណត់របស់សវនាការនៅពេលនេះ។ ចៅក្រមបានប្រាប់ទៅមេធាវីថា មិនត្រូវសួរសំណួរដែល“បង្កើតឲ្យមានការប៉ាន់ស្មាន”សម្រាប់សាក្សីទេ ហើយចៅក្រមបានរំឭកទៅមេធាវីទាំងអស់ឲ្យប្រើប្រាស់ពេលវេលាឲ្យបានត្រឹមត្រូវ។

មេធាវី ផេសមិន បានបញ្ជាក់ថា គាត់មិនមានសំណួរអ្វីទៀតទេ ដូច្នេះចៅក្រមបានប្រគល់នាទីនេះទៅឲ្យមេធាវីរបស់ អៀង សារី ដើម្បីសួរសំណួរ។

## មេធាវីរបស់ អៀង សារី ប្រឆាំងនឹងភ័ស្តុតាង និងសួរទៅសាក្សី

អាង ឧត្តម មេធាវីរបស់ អៀង សារី ចាប់ផ្តើមសួរ តែមិនមែនសួរសាក្សីទេ គឺសួរអំពី«ការសង្កេតឃើញខ្លះៗ»របស់គាត់។ មេធាវី អាង ឧត្តម បានបញ្ជាក់ថា ក្រុមការពារក្តីរបស់ អៀង សារី បានស្តាប់រួចហើយនូវការសម្ភាសន៍ជាមួយសាក្សី ឡុង នរិន្ទ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយគាត់បានយកចម្លើយនោះមកប្រៀបធៀបគ្នាទៅនឹងអត្ថបទដែលចម្លងចេញពីការសម្ភាសន៍នោះ គាត់បានជម្រាបទៅតុលាការថា ក្រុមមេធាវីរបស់ អៀង សារី ប្រើប្រាស់អត្ថបទចម្លងចេញពីបទសម្ភាសន៍នោះធ្វើជាឯកសារយោងដើម្បីសួរសំណួរទៅសាក្សី។ អាង ឧត្តម សង្កេតឃើញថា អត្ថបទនោះមិនត្រូវបានបកប្រែជាភាសាបារាំង និងអង់គ្លេសទេ។ មេធាវីការពារក្តីក៏បានប្រៀបធៀបអត្ថបទសម្ភាសន៍សង្ខេបនោះ ដោយការិយាល័យព្រះរាជអាជ្ញា ដែលសហព្រះរាជអាជ្ញាបានយកមកយោងពេលសួរនាំទៅសាក្សី។

ក្រោយមក អាង ឧត្តម បានជម្រាបទៅចៅក្រមថា គាត់រកឃើញកំហុសខ្លះ ហើយគាត់បានជម្រាបជាលាយលក្ខណ៍អក្សររួចហើយ តែកំហុសនោះ«មិនមានអ្វីជាធំដុំទេ»។ ក្តីបារម្ភសំខាន់គឺថា អ្នកបកប្រែនៅពេលសម្ភាសន៍នោះ មិនត្រឹមតែបកប្រែពេលសម្ភាសន៍ប៉ុណ្ណោះទេ តែថែមទាំងសួរ និងឆ្លើយសំណួរ និង«សរសេរពាក្យ»សម្រាប់អ្នកសម្ភាសន៍ផង។ ក្នុងអត្ថបទដែលចម្លងចេញពីកាសែតចំនួន៩៨ទំព័រនោះ អាង ឧត្តម បាននិយាយថា ការនិយាយរបស់អ្នកធ្វើសម្ភាសន៍ត្រូវបានថតសំឡេង ហើយមានស្ទើរគ្រប់ទំព័រ។ ក្រោយពីជូនឧទាហរណ៍ច្បាស់ដូច្នេះហើយ អាង ឧត្តម បានភ្ជាប់ការជំទាស់នេះទៅនឹងអ្វីដែលក្រុមមេធាវីរបស់របស់ អៀង សារី បានជំទាស់កាលពីលើកមុនប្រឆាំងនឹងដំណាក់កាលស៊ើបអង្កេតក្នុងសវនាការ០០២។ អាង ឧត្តម បានស្នើទៅអង្គសវនាការឲ្យបើកសវនាការមួយទាក់ទងនឹងសហចៅក្រមស៊ើបអង្កេតអំពីករណីនេះ ហើយគាត់បានអំពាវនាវទៅតុលាការឲ្យផ្តល់ការយល់ព្រមទៅនឹងសំណើរបស់ អៀង សារី ដើម្បីឲ្យមានការ«ស៊ើបអង្កេតលើកទីបី»។

ត្រង់ចំណុចនេះ ឌេល លីសាក់ បានជំទាស់នឹង អាង ឧត្តម ដោយអះអាងថា «ពេលនេះមិនមែនជាពេលដែលត្រូវថ្លែងសុន្ទរកថាទេ»។ ចៅក្រម និល ណុន បាននិយាយថា ការពិភាក្សាពីបញ្ហាច្បាប់នេះគួរតែលើកមកនិយាយនៅពេលក្រោយ ហើយគាត់បានណែនាំមេធាវីការពារក្តីថា គួរតែសួរសំណួរទៅសាក្សីឥឡូវនេះ បើមិនដូច្នេះទេ តុលាការនឹងប្រគល់តួនាទីនេះទៅក្រុមការពារក្តីផ្សេងទៀត។

មេធាវីអន្តរជាតិរបស់ អៀង សារី ឈ្មោះ ម៉ៃខល ការណាវ៉ាស បានបន្តពី អាង ឧត្តម ដើម្បីសួរសំណួរទៅសាក្សី។ មុននឹងចាប់ផ្តើមសួរសំណួរ មេធាវី ការណាវ៉ាស បានពិនិត្យមើលឡើងវិញពីបញ្ហាដែលមានកាលពីលើកមុន ហើយគាត់បាននិយាយថា គាត់ហើយនឹងសហការីរបស់គាត់បានយល់ស្របជាមួយព្រះរាជអាជ្ញាថា អត្ថបទសម្ភាសន៍របស់ ឡុង នរិន្ទ គួរតែបកប្រែជាភាសាអង់គ្លេស ដូច្នេះចៅក្រម

ទាំងអស់អាចមើលឯកសារនោះបាន។ ក្រោយមក មេធាវី កាណាវ៉ាស ចាប់ផ្តើមសួរសំណួរទៅកាន់សាក្សីថា មានដែលស្តាប់ការសម្ភាសក្នុងឆ្នាំ២០០៧របស់ខ្លួនទេ។ ឡុង នរិន្ទ បានបញ្ជាក់ថា គាត់មិនដែលបានស្តាប់អត្ថបទសម្ភាសន៍ ហើយនិងអានពេញទាំង៩៨ទំព័រនោះសោះ ហើយក៏មិនដែលអានអត្ថបទសង្ខេបរបស់ការិយាល័យសហព្រះរាជអាជ្ញាដែរ ។

នៅពេលសួរថា តើគាត់មានដែលនិយាយទៅកាន់នរណាម្នាក់ទេតាំងពីឆ្នាំ១៩៧៩មក ទាក់ទងនឹងរបបពីឆ្នាំ១៩៧៥-១៩៧៩ ឡុង នរិន្ទ បានឆ្លើយថា គាត់មិនដែលអាន និងសន្ទនាជាមួយនរណាម្នាក់ពីបញ្ហានេះទេ។ តែពេលដែលសួរពីបញ្ហានេះទៀត សាក្សីបានឆ្លើយតបថា គាត់មិនចាំទេ។ មេធាវី កាណាវ៉ាស បានសួរទៀតថា «តើវាត្រូវទេដែលខ្ញុំនិយាយថាលោកមិនចាំរឿងច្រើនណាស់?» ឡុង នរិន្ទ បានឆ្លើយដោយសាមញ្ញថា «ខ្ញុំអត់ចាំទេ» ។ តែនៅពេលដែល មេធាវី កាណាវ៉ាស សួរថា តើគាត់អាចប្រទាំជាមួយហេតុការណ៍ខ្លះមួយចំនួនទេ ឡុង នរិន្ទ ហាក់បីដូចជាបដិសេធនូវចំណុចនេះ ដោយបញ្ជាក់ថា «ខ្ញុំមិនដឹងថាតើលោកចង់និយាយពីកន្លែងប្រទាំណាមួយទេ» ។

ក្រោយមក មេធាវី កាណាវ៉ាស ត្រឡប់ទៅសួរពីពេលដែលសាក្សីនៅបរទេសថា តើសាក្សីមានចាំទេថា គាត់ចាកចេញពីទីក្រុងប្រាកទៅកាន់ទីក្រុងប៉េកាំងនៅពេលណា។ សាក្សីមិនបានឆ្លើយទេទោះបីជាមេធាវីសួរឡើងវិញក៏ដោយ ។ មេធាវី កាណាវ៉ាស បាននិយាយថា សំណួរសម្រាប់ថ្ងៃនេះចប់ហើយ ។ មេធាវីការពារក្តីយល់ឃើញថា សាក្សីហាក់បីដូចជាមានការលំបាកក្នុងការឆ្លើយសំណួរ ទោះបីជាសំណួរនោះមានលក្ខណៈសាមញ្ញក៏ដោយ ហើយកាលពីថ្ងៃម្សិលមិញគាត់មិនមានបញ្ហាអ្វីក្នុងការឆ្លើយសំណួរទេ។ មេធាវី កាណាវ៉ាស និយាយថា ឡុង នរិន្ទ គួរតែមកធ្វើសក្ខីកម្មម្តងទៀតនៅពេលក្រោយ ។

ខ្ទេល លីសាក់ បានជំទាស់នឹងពាក្យសុំរបស់ មេធាវី កាណាវ៉ាស ដោយបញ្ជាក់ថា វាមិនត្រឹមត្រូវទេដែលនិយាយបែបនេះ។ មេធាវី កាណាវ៉ាស បានឆ្លើយតបដោយស្នើទៅចៅក្រម និល ណុន ថា តើសាក្សីអាចបន្តធ្វើសក្ខីកម្មនៅពេលក្រោយទៀតបានដែរឬទេ។

ចៅក្រម និល ណុន បានងាកទៅសាក្សីដោយសួរថា តើគាត់យល់សំណួរឬក៏អត់។ ឡុង នរិន្ទ បានឆ្លើយថា គាត់មិនយល់ទេ។ ក្រោយមកចៅក្រម និល ណុន បានបញ្ជាក់ថា ការធ្វើសក្ខីកម្មជាមួយសាក្សី ឡុង នរិន្ទ អាចបញ្ចប់នៅព្រឹកនេះ ហើយគាត់បានសួរទៅសាក្សីថា តើគាត់អាចស្តាប់ដោយយកចិត្តទុកដាក់បន្តិច និងបន្តសួរសំណួរទៀតបានដែរឬទេ។ ឡុង នរិន្ទ បានបញ្ជាក់ថា «ខ្ញុំឈឺក្បាល និងឈឺ-ក» ។

ទោះបីជាសាក្សីនិយាយបែបនេះហើយក៏ដោយ ចៅក្រម និល ណុន សម្រេចថា បន្តសួរសំណួរទៅសាក្សីបន្តទៀត ហើយបានស្នើឲ្យបុគ្គលិករបស់អង្គភាពគាំពារកសាក្សីនិងអ្នកជំនាញ ដែលនៅជាមួយ

សាក្សីស្រាប់ ឲ្យរំកិលម៉ៃក្រូហ្វូន និងប្រដាប់បំពងសំឡេងទៅកៀកសាក្សី ហើយគាត់បានណែនាំឲ្យសួរទៅសាក្សីខ្លីៗ ។

មេធាវី កាណាវ៉ាស បានបន្តសួរទៀតថាតើសាក្សីនឹកឃើញទេថា គាត់ចាកចេញពីទីក្រុងប្រាកទៅប៉េកាំងឆ្នាំ១៩៧១ឬ ។ ឡុង នរិន្ទ បានឆ្លើយដោយរៀបរាប់ពីពេលដែលគាត់រស់នៅបរទេសម្តងទៀត តែគាត់មិនបានឆ្លើយឲ្យចំសំណួរនេះទេ ។ ចៅក្រម និល ណុន បានប្រាប់ទៅសាក្សីឲ្យស្តាប់សំណួរឲ្យច្បាស់ ហើយឆ្លើយអ្វីដែលបានសួរទៅបានហើយ ។

មេធាវី កាណាវ៉ាស បានសួរទៅសាក្សីទៀតថាតើពេលដែលគាត់នៅទីក្រុងប៉េកាំង គាត់មានទំនាក់ទំនងជាមួយសម្តេច សីហនុ ទេនៅពេលនោះ ។ ឡុង នរិន្ទ បានឆ្លើយថា គាត់បានជួប ។ តែនៅពេលសួរថាតើគាត់បានឃើញនិងចូលរួម«ពីធីមហាជប់លៀង» ដែលសម្តេចជប់លៀងសម្រាប់«កូនចៅ»របស់ព្រះអង្គដែរឬទេ ។ ឡុង នរិន្ទ បានរៀបរាប់ថា គាត់មិនចាំទេ ហើយគាត់នឹកមិនឃើញទេថា តើសម្តេច សីហនុ មានបានហៅគាត់«គ្រប់ពេលដើម្បីលេងកីឡា» ដែរឬទេ ជាពិសេសកីឡាបាល់ទាត់ ។

មេធាវី កាណាវ៉ាស បានសួរទៀតថា តើសាក្សីមានចាំថាមានបាននិយាយជាមួយអ្នកនិពន្ធម្នាក់ឈ្មោះ ហ្វីលីព សត ដែរឬទេ ពេលនោះបុគ្គលិករបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានអានសំណួរនោះឡើងវិញទម្រាំតែ ឡុង នរិន្ទ យល់សំណួរ ។ ឡុង នរិន្ទ បានរៀបរាប់ថា គាត់មិនចាំថាបាននិយាយជាមួយអ្នកនិពន្ធណាខ្លះទេ ហើយគាត់ក៏មិនចាំដែរថាគាត់បាននិយាយជាមួយ ហ្វីលីព សត អំពីទីតាំងមន្ទីរ ប-១៥ និងប-២០នោះ ។ តែ ឡុង នរិន្ទ បញ្ជាក់ថា គាត់មិនច្រឡំទេរវាងទីតាំងទាំងពីរនេះ ។

ទាក់ទងនឹងពេលដែលសាក្សីនៅក្រសួងការបរទេសវិញ មេធាវី កាណាវ៉ាស បានសួរទៅសាក្សីថា តើគាត់គ្រាន់តែជាអ្នក«វាយអង្គុយលីលេខតែមួយមុខប៉ុណ្ណោះ»ឬយ៉ាងណា ។ ឡុង នរិន្ទ មិនបានយល់សំណួរនេះទេ តែគាត់បានឆ្លើយថា គាត់ត្រូវប្រជុំផ្សេងៗអំពីគោលនយោបាយនានា ។

ក្រោយមក មេធាវី កាណាវ៉ាស បានសួរថា «តើលោកមានស្គាល់នរណាទៀតដែលធ្វើការនៅក្រសួងការបរទេសដែលដឹងរឿងច្រើនជាងលោកដែរឬទេ» ។ សំណួរនេះត្រូវបានសហព្រះរាជអាជ្ញាជំទាស់ដោយអះអាងថា សំណួរនេះមិនត្រូវសួរទៅកាន់សាក្សីទេ ។

មេធាវី កាណាវ៉ាស បានសួរទៅសាក្សីទៀតថា តើរវាងគាត់ហើយនិង អៀង សារី ខុសគ្នាប៉ុន្មានកម្រិតនៅក្រសួងការបរទេស ។ សាក្សីបានរៀបរាប់ឈ្មោះមេរបស់គាត់ ហើយបញ្ជាក់ថា គាត់មិនស្គាល់មេៗដែលនៅពីលើនោះទៀតទេ ។ ឡុង នរិន្ទ បានឆ្លើយថា «ប្រហែលជាទៅសួរគាត់ទើបដឹង» ។ នៅពេលសួរថាតើក្មួយរបស់ ប៉ុល ពត ធ្វើការនៅក្រសួងការបរទេសដែរមែនទេ ឡុង នរិន្ទ បាននិយាយថា «ក្មួយរបស់ ប៉ុល ពត មានឈ្មោះនៅក្រសួងការបរទេស តែយើងមិនដែលឃើញគាត់មកធ្វើការ

ទេ» ។ មេធាវី កាណាវ៉ាស បានសួរសំណួរចុងក្រោយថា «តើលោកអាចនិយាយបានទេថា ដោយសាររឿងរ៉ាវកន្លងទៅច្រើនឆ្នាំពេក លោកមានការភាន់ច្រឡំនូវហេតុការណ៍ខ្លះ តើមែនដែរឬទេ» ។ ឡុង នរិន្ទ បានឆ្លើយថា «មានការភាន់ច្រឡំខ្លះហើយ» ។

ពេលដែលក្រុមមេធាវីការពារក្តីរបស់ អៀង សារី សួរចប់ភ្លាម ចៅក្រម និល ណុន បានប្រកាសសវនាការឲ្យសម្រាកនៅពេលព្រឹកដើម្បីឲ្យសាក្សីសម្រាក ។ ពេលចៅក្រមហៀបនឹងដើរចេញពីបន្ទប់សវនាការ មេធាវីអន្តរជាតិរបស់ ខៀវ សំផន ឈ្មោះ អាកទួរ វែកគែន បានបញ្ជាក់ថា ក្រុមរបស់គាត់«គ្មានបំណងនឹងធ្វើឲ្យសាក្សីឈឺយូរទេ» ហើយពេលនោះគាត់ស្នើទៅតុលាការឲ្យសាក្សីទៅសម្រាក ។ មេធាវី អាកទួរ វែកគែន បាននិយាយថា ក្រុមមេធាវីរបស់របស់ ខៀវ សំផន មិនមានសំណួរអ្វីទៅកាន់សាក្សី ឡុង នរិន្ទ ទេ ។ ពេលនោះចៅក្រមបានឆ្លើយតបថា គាត់ជឿថា «មេធាវីការពារក្តីគួរតែយល់ច្បាស់ហើយពីបញ្ហានេះ» ។

## សួរដោយអង្គុយលើកៅអីបង្កឲ្យមានការពិភាក្សាទាក់ទងទៅនឹងអត្ថបទសម្ភាសន៍សង្ខេប

ក្រោយពីពិភាក្សាជាមួយចៅក្រមផ្សេងទៀតរួចមក ចៅក្រម និល ណុន បានជម្រាបទៅសាក្សីថា នៅមានសំណួរពីរបីទៀត ។ ភ្លាមនោះ ចៅក្រម ឡាវែន៍ បានសួរទៅសាក្សីដើម្បីឲ្យគាត់បញ្ជាក់ឡើងវិញទាក់ទងទៅនឹងការសម្ភាសន៍កាលពីឆ្នាំ២០០៧ ដោយគាត់បានអានអត្ថបទសម្ភាសន៍នោះឲ្យសាក្សីស្តាប់ ហើយគាត់ក៏បានទទួលសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរមួយដែរ ។ នៅពេលដែល ឡុង នរិន្ទ បញ្ជាក់ថា គាត់មិនចាំពីពេលដែលគាត់បានសម្ភាសន៍កាលពីឆ្នាំ២០០៧ទេ ហើយចៅក្រមបានសួរទៅបុគ្គលិករបស់អង្គភាពសាក្សី និងអ្នកជំនាញថា តើសាក្សីមានឯកសារនោះនៅក្នុងដៃទេ ។

មេធាវី កាណាវ៉ាស និយាយកាត់ដោយបញ្ជាក់ថា អ្វីដែលចៅក្រមកំពុងតែនិយាយនេះ មិនមាននៅក្នុងអត្ថបទចម្លងចេញពីការសម្ភាសន៍ដែលមាន៩៨ទំព័រទេ ។ ចៅក្រម ឡាវែន៍ បានបញ្ឈប់មេធាវីកណ្តាលទីហើយបន្ទោសទៅមេធាវីថា «លោកបានស្តាប់ខ្ញុំនិយាយទេ ។ ខ្ញុំមិនបាននិយាយដូចលោកអះអាងទេ» ។ ក្រោយមក បុគ្គលិករបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានផ្តល់សញ្ញាទៅចៅក្រមថា សាក្សីមានឯកសារសម្ភាសន៍នោះហើយ ហើយពេលនោះចៅក្រម ឡាវែន៍ បានសួរទៅសាក្សីថា តើគាត់ចាំហត្ថលេខានៅទំព័រចុងក្រោយនេះទេ ។ ក្រោយពីមើលឯកសារនោះរួចមក ឡុង នរិន្ទ បានអះអាងបញ្ជាក់ថា នេះគឺជាហត្ថលេខានិងស្នាមមេដៃរបស់គាត់ ហើយថាគាត់ចាំថាគាត់បានចុះហត្ថលេខានៅលើឯកសារនោះ ដោយគ្មាននរណាបង្ខំគាត់ឲ្យចុះហត្ថលេខា និងផ្តិតមេដៃទេ ។ តែគាត់មិនចាំទេថា អ្នកសម្ភាសន៍គាត់បានចាក់សំឡេងឲ្យគាត់ស្តាប់ឬអត់ ។ គាត់ហាក់បីដូចស្ទាក់ស្ទើរត្រង់ថា «ពាក្យពេចន៍ដែលគាត់និយាយនោះពិតឬអត់ទេ» ពេលដែលគាត់ប្រាប់អ្នកស៊ើបអង្កេតនោះ ។

មេធាវី កាណាវ៉ាស បានក្រោកឈរហើយថ្លែងពីក្ដីបារម្ភថា ឡុង នរិន្ទ មិនអាចអានឯកសារសម្ភាសន៍នោះទាំងអស់បានទេ ។ មេធាវី កាណាវ៉ាស បានបញ្ជាក់ថា«ខ្ញុំច្របូកច្របល់អស់ហើយ» ព្រោះតុលាការហាក់បីដូចជាពឹងផ្អែកទៅលើអត្ថបទសម្ភាសន៍សង្ខេបដែលជាភ័ស្តុតាង «មិនត្រឹមត្រូវទាល់តែសោះ» ជាពិសេសនៅពេលដែលសាក្សីនឹកមិនឃើញនូវអ្វីដែលគាត់ធ្លាប់និយាយ ។

ព្រះរាជអាជ្ញាបានឆ្លើយតបថា សំឡេងដែលថតនោះមានលក្ខណៈច្បាស់ហើយ ដូច្នេះសាក្សីមិនចាំបាច់អានអត្ថបទសម្ភាសន៍ឡើងវិញទេ ហើយមេធាវី កាណាវ៉ាស មិនបាច់មានសំណួរបន្ថែមទេ ។ ឌេល លីសាក់ បានបញ្ជាក់ថា ភាគីទាំងអស់មិនគួរនិយាយបែបនេះនៅចំពោះមុខសាក្សីទេ ហើយគាត់មិនជំទាស់ទៅនឹងសំណើដែលថា ឯកសារនោះគួរតែមានច្រើនភាសាទេ ។ ឌេល លីសាក់ បាននិយាយទៀតថា ការសង្ខេបសម្ភាសន៍សម្រាប់ភ័ស្តុតាងនោះគឺ «ដំណើរការតាមបទដ្ឋាននៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ» ។

មេធាវី កាណាវ៉ាស បានបន្តដោយនិយាយពីប្រធានបទដែលបានលើកដោយសហមេធាវីរបស់គាត់ដែលបញ្ជាក់ថា «អ្វីដែលជាការព្រួយបារម្ភគឺថា អ្នកស៊ើបអង្កេតកំពុងតែផ្ដល់ចម្លើយ និងបង្អាក់សាក្សីមិនឲ្យនិយាយ ហើយក្រោយមកធ្វើពុតថា សេចក្ដីសង្ខេបនោះឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវ» ។ មេធាវី កាណាវ៉ាស បានបញ្ជាក់ថា ក្ដីបារម្ភរបស់ក្រុមគាត់គឺថា អត្ថបទសង្ខេបនោះមានអ្នកបកប្រែជាច្រើននាក់ ហើយមិនមានឱកាសមើលឯកសារនោះជាភាសារបស់ខ្លួនទេ ។

ចៅក្រម និល ណុន នៅតែរក្សាការជំទាស់របស់គាត់ជាមួយសហព្រះរាជអាជ្ញា ហើយបានបញ្ចប់ការពិភាក្សានៅពេលនេះ ។ ចៅក្រមបានថ្លែងអំណរគុណដល់សាក្សី ហើយជម្រាបទៅសាក្សីឲ្យសម្រាក ហើយចៅក្រមក៏ប្រកាសឲ្យសវនាការសម្រាកដែរ ។

## ព្រះរាជអាជ្ញាចាប់ផ្ដើមសួរសំណួរទៅ នួន ជា

ក្រោយពីសម្រាករួច ចៅក្រម និល ណុន បានប្រគល់តួនាទីនេះទៅសហព្រះរាជអាជ្ញាបន្តសួរនាំទៅ នួន ជា បន្តទៀត ។ មុននឹងបន្ត ឌេល លីសាក់ បានប្រគល់ឯកសារចម្លងពីការសម្ភាសន៍ជាមួយ ឡុង នរិន្ទ ក្នុងឆ្នាំ២០០៧ នៅចំពោះមុខតុលាការ ។

មេធាវី កាណាវ៉ាស បានក្រោកឈរ ហើយចាប់ផ្ដើមជំទាស់ តែគាត់ត្រូវចៅក្រម និល ណុន បន្ទោសដោយសារតែគាត់មិនបានសុំអនុញ្ញាតចៅក្រមមុននឹងឡើងនិយាយ ។ ចៅក្រមបានប្រាប់ទៅមេធាវី កាណាវ៉ាស «លោកត្រូវចេះគួរសមបន្តិច» ។

មេធាវី កាណាវ៉ាស បានស្នើឲ្យមានការបកប្រែអត្ថបទសម្ភាសន៍នោះមុននឹងយកមកបង្ហាញនៅចំពោះមុខតុលាការ ហើយពេលនោះសហព្រះរាជអាជ្ញាបានចាប់ផ្ដើមសួរសំណួរទៅ នួន ជា ។

មុនដំបូង ខ្ទេល លីសាក់ បានសួរសំណួរអំពីប្រវត្តិរូបរបស់ នួន ជា ។ ខ្ទេល លីសាក់ បានសួរទៅ នួន ជា ថា ពេលដែលគាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា តើគាត់មានដែលទទួលបានប្រវត្តិរូបរបស់កម្មាភិបាល ហើយសួរចម្លើយអ្នកនោះអំពីនិន្នាការនយោបាយអ្វីទេ ។ នួន ជា បានឆ្លើយថា ការសួរចម្លើយមិនមែនជាកិច្ចការរបស់គាត់ទេ ព្រោះគាត់ស្ថិតនៅក្នុង«នីតិបញ្ញត្តិ» មិនមែននៅក្នុង«រដ្ឋបាល»ទេ ។ មានតែផ្នែករដ្ឋបាលទេទើបមាននាទីសួរចម្លើយ ។ នួន ជា បាននិយាយទៀតថា អ្នកដែលចូលបក្សត្រូវតែសរសេរប្រវត្តិរូប ដូច្នេះទើបបក្សដឹងពី«លក្ខណៈសម្បត្តិ និន្នាការ និងជំហរ» និង«ដើម្បីជួយបក្សក្នុងការអប់រំតាមលក្ខណៈសម្បត្តិរបស់សមាជិក» ។ បក្សចាប់ផ្ដើមធ្វើប្រវត្តិរូបមុនឆ្នាំ១៩៦០ទៅទៀត ។

នៅពេលសួរថាតើប្រវត្តិរូបយកមកដើម្បីមើលថាតើសមាជិកណាស្ថិតនៅក្នុង«ថ្នាក់»ណាមួយឬ នួន ជា បានឆ្លើយថា ថ្នាក់សង្គមរបស់កម្មាភិបាលមិនមែនជាលក្ខណៈសម្បត្តិក្នុងការចូលបក្សកុម្មុយនីស្តកម្ពុជាទេ តែសំខាន់នោះគឺថា«អ្នកនោះមានទស្សនៈនិងជំហរមិនមែនមូលធននិយម» ។ សមាជិកបក្សត្រូវលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដោយគិតពី«ប្រយោជន៍សមូហភាព»វិញ ហើយសមាជិកបក្សមិនត្រូវ«ផឹកស្រា ញៀនស្រី និងធ្វើសកម្មភាពមិនគប្បីអ្វីទៀតទេ» ។ បើសិនជាប្រវត្តិរូបនោះមានជាប់ទាក់ទងជាមួយសមាសភាពអាក្រក់ «យើងត្រូវតែរំឭកអ្នកនោះឲ្យបោះបង់ចោលគំនិតនោះ និងចាប់យកគំនិតបដិវត្តន៍វិញ» ។ ខ្ទេល លីសាក់ បានសួរអំពីគោលការណ៍«មជ្ឈិមប្រជាធិបតេយ្យ»របស់មាត្រា៦ នៃលក្ខន្តិកៈ«គោលការណ៍មជ្ឈិម»របស់បក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា បានពន្យល់ថា គោលការណ៍នេះគឺសំដៅទៅលើ«សមូហភាពនៃចំណេះដឹង ទស្សនៈ និងគំនិត» ពីសមាជិកបក្សទាំងអស់ ។ នៅពេលសួរថាតើគោលការណ៍សមូហភាពនៃការសម្រេចចិត្តជារួម ដូចចែងនៅក្នុងមាត្រាទី៦(២)នៃលក្ខន្តិកៈ គឺជាផ្នែកមួយនៃមជ្ឈិមប្រជាធិបតេយ្យឬ ជនជាប់ចោទបាននិយាយថា សេចក្ដីសម្រេចទាំងអស់របស់បក្ស«មិនត្រូវធ្វើដោយបុគ្គលតែម្នាក់ឯងទេ» ។ គោលការណ៍នេះត្រូវបានបង្កើតនិងអនុវត្តនៅគ្រប់អង្គប្រជុំទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជារួមទាំងអ្នកដែលជាសមាជិកមជ្ឈិមនិងគណៈអចិន្ត្រៃយ៍ផង ។ នួន ជា បានអះអាងទៀតថា «បក្សបានប្រកាន់ភ្ជាប់គោលការណ៍ជាប់លាប់ណាស់ ដែលជាគោលការណ៍សាកលនៅពេលនោះ» ។ ក្រោយមក នួន ជា រៀបរាប់អំពីដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តជារួម ដោយពន្យល់ពីរបៀបដែលបក្សសម្រេចយកគំនិតណាមួយ ។ បើសិនជាសមាជិកណាមួយមិនយល់ស្របនឹងគំនិតណាមួយនោះ នឹងមានការពិភាក្សាគ្នារហូតឈានដល់កិច្ចព្រមព្រៀងមួយ ។ ក្រោយមកទើបសេចក្ដីសម្រេចនោះមានលក្ខណៈជាផ្លូវការ ។

ក្រោយមកសហព្រះរាជអាជ្ញាបានសួរទៅ នួន ជា ពីពេលដែលគាត់នៅវៀតណាមក្នុងឆ្នាំ១៩៥១ ដល់១៩៥៣ ។ ជនជាប់ចោទបានរៀបរាប់ថា គាត់ចង់ទៅវៀតណាមក្នុងឆ្នាំ១៩៥១ តែគាត់មិនបានទៅទេ ក្រោយមកនៅឆ្នាំ១៩៥៣ទើបគាត់អាចទៅរៀននៅទីនោះបាន ។ ពេលនៅវៀតណាម គាត់រៀន«នៅ

ក្នុងព្រៃ» ហើយពេលនោះគាត់រៀនពីកម្មាភិបាលវៀតណាមជាច្រើននាក់ ដែលធ្លាប់ទៅរៀននៅប្រទេសចិន។ ការរៀនសូត្រនោះ គឺធ្វើឲ្យសិស្សដឹងពីជីវិតរបស់ខ្លួន ដូចជា «ការដឹកស្រា» «ញៀនស្រី» «ការមិនអនុវត្តតាមគោលការណ៍បក្ស» ឬ«ជួបជាមួយសត្រូវ» ជាដើម។ នៅពេលសួរថា តើគាត់មានបានរៀនពីការធ្វើសង្គ្រាមឈ្លបទេពេលដែលគាត់នៅប្រទេសវៀតណាម នួន ជា បានឆ្លើយថា គាត់មិនយល់ពីពាក្យនោះមានន័យថាយ៉ាងម៉េចទេ។ ព្រះរាជអាជ្ញាបានសួរម្តងទៀតថា តើគាត់មានបានប្រាប់ ថេត សម្បត្តិ ថា គាត់រៀនពីការធ្វើសង្គ្រាមនៅវៀតណាមដែរឬទេ។ នួន ជា បានកែព្រះរាជអាជ្ញាវិញ ដោយបញ្ជាក់ថា គាត់រៀនពីការធ្វើសង្គ្រាមយោធា មិនមែនជាសង្គ្រាមឈ្លបទេ តែគាត់បានមិនបានរៀនសូត្រដោយផ្ទាល់ទេ គាត់គ្រាន់តែឮពីអ្នកដែលបានទៅរៀនប៉ុណ្ណោះ។ នួន ជា បាននិយាយទៀតថា ការធ្វើសង្គ្រាមយោធារួមមាន ការយកកម្លាំងទ័ពតិចទៅវាយកម្លាំងទ័ពច្រើន ឬ«ប្រើប្រាស់គុណភាពទៅប្រយុទ្ធជាមួយបរិមាណ»។ យុទ្ធសាស្ត្រនោះគឺថាត្រូវវាយឲ្យរហ័ស ប្រមូល«កេតនភណ្ឌ»ឲ្យរហ័ស រួចដកឲ្យរហ័សដែរ។ មេធាវីរបស់ នួន ជា ឈ្មោះ សុន អរុណ បាននិយាយកាត់ត្រង់ចំណុចនេះ ដោយជំទាស់ទៅនឹងការប្រើប្រាស់សៀវភៅរបស់ ថេត សម្បត្តិ ដែលធ្លាប់បង្កឲ្យមានការពិភាក្សាច្រើនមកហើយកាលពីម្សិលមិញ។ មេធាវី សុន អរុណ បាននិយាយថា សៀវភៅនោះមានជាភាសាអង់គ្លេស ហើយគ្មានព័ត៌មានណាមួយដែលសហព្រះរាជអាជ្ញារកឃើញនៅក្នុងសៀវភៅនេះទេ។

តុលាការយល់ស្របទៅនឹងការជំទាស់នេះ ហើយតុលាការបានរំឭកទៅព្រះរាជអាជ្ញាថា ចៅក្រមខាតវ៉ាយថ៍ បានជម្រាបរួចហើយថា ព្រះរាជអាជ្ញាអាចប្រើសៀវភៅនោះដើម្បីភ្ជាប់ទំនាក់ទំនងរវាង នួន ជា និង ថេត សម្បត្តិ ប៉ុណ្ណោះ តែមិនត្រូវយកខ្លឹមសារដែលមាននៅក្នុងសៀវភៅនោះមកនិយាយទេ ព្រោះតុលាការមិនទាន់សម្រេចអំពីការដាក់បញ្ចូលសៀវភៅនោះនៅឡើយទេ។ ខេល លីសាក់ បានបញ្ជាក់ថា គាត់នឹងមិនប្រើសៀវភៅនោះទៀតទេ បើសិនជាតុលាការមិនទាន់សម្រេចទទួលយកសៀវភៅនេះទេ ហើយគាត់បានជម្រាបទៅមេធាវីរបស់ជនជាប់ចោទថា គាត់ឃើញសៀវភៅនោះនៅក្នុងបណ្ណាល័យរបស់តុលាការ ហើយគាត់ក៏ចាប់ផ្តើមសួរសំណួរទៅជនជាប់ចោទបន្តទៀត។

ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថាតើគាត់រៀននៅវៀតណាមចប់ឬទេ។ នួន ជា បានឆ្លើយថា ការបង្រៀននោះធ្វើឡើងជាភាសាខ្មែរ។ ពេលដែលរៀនជាភាសាវៀតណាម ការពិភាក្សាផ្សេងៗធ្វើឡើងជាភាសាខ្មែរដដែល។ នួន ជា បញ្ជាក់ថា គាត់ចេះភាសាវៀតណាមខ្លះៗដែរ ហើយគាត់នឹកឃើញថា គាត់បានចំណាយពេលរៀនភាសាវៀតណាមខ្លះដែរ ពេលដែលគាត់ចូលបដិវត្តន៍ក្នុងឆ្នាំ១៩៥១ ពេលដែលខ្មែរនិងវៀតណាមធ្វើការជាមួយគ្នា ហើយពេលនោះគាត់ចំណាយពេលមួយម៉ោងជារៀងរាល់ព្រឹកដើម្បីរៀនភាសាផ្សេងទៀត។

ខេល លីសាក់ បានសួរទៅជនជាប់ចោទថា នៅពេលណាទើបគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ នៅពេលដែលឯករាជ្យពីបារាំងត្រូវបានទទួលស្គាល់ ។ នៅពេលសួរថា តើគាត់មានត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការបក្សប្រជាជនបដិវត្តន៍ខ្មែរប្រចាំនៅទីក្រុងភ្នំពេញដែរឬទេ នួន ជា ហាក់បីដូចជាមានអារម្មណ៍រួញរា ហើយបញ្ជាក់ថា គាត់បានប្រាប់តុលាការហើយថា នៅពេលនោះ គាត់ និង សាឡុត ស កំពុងតែជួយ ទូ សាមុត ហើយ នួន ជា បាននិយាយថា “ខ្ញុំមិនចាំបាច់និយាយម្តងទៀតទេ” ហើយថា សំណួរនេះហាក់បីដូចជា“ច្រំដែល” និង“ខាតពេល” ។ នៅពេលសួរថាតើ អៀង សារី ធ្លាប់ចូលរួមជាមួយគាត់ និង សាឡុត ស ក្នុងបក្សប្រជាជនបដិវត្តន៍ខ្មែរនៅទីក្រុងភ្នំពេញដែរឬទេ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា គាត់មិនទាន់ស្គាល់ អៀង សារី ទេ នៅពេលនោះ “ខ្ញុំឮតែឈ្មោះគាត់ប៉ុណ្ណោះ តែមិនដែលជួបមុខគាត់ទេ” ។ ទោះជាមានសំណួរជាច្រើនក្រោយមកទៀតក៏ដោយ ក៏ នួន ជា នៅតែនិយាយថា គាត់ទើបតែជួប អៀង សារី ក្រោយពីបក្សបានរៀបចំឡើងវិញក្នុងឆ្នាំ១៩៥៩ប៉ុណ្ណោះ ។

ក្រោយមក ខេល លីសាក់ បាននិយាយសម្អាងទៅលើឯកសារមួយដែលព្រះរាជអាជ្ញាបានលើកមកនិយាយកាលពីម្សិលមិញដែលនៅក្នុងឯកសារនោះមានការសន្ទនាគ្នារវាង នួន ជា និង ខឹម ងួន ក្នុងឆ្នាំ១៩៩៨ ។ ពេល ខេល លីសាក់ រៀបនឹងប្រាប់ពីលេខរបស់ឯកសារនោះ ជនជាប់ចោទ នួន ជា បានបដិសេធដោយនិយាយថា “ខ្ញុំមិនដែលស្គាល់ ខឹម ងួន ទេ” ។ ខេល លីសាក់ បានបន្តទៀត ហើយឯកសារនេះជាភាសាខ្មែរត្រូវបានបញ្ចាំងនៅលើអេក្រង់ ។ ពេលនោះ នួន ជា បាននិយាយសាឡើងវិញថា ខឹម ងួន គឺជាគិញរបស់ ហ៊ុន សែន ។ នួន ជា បាននិយាយទៀតថា គាត់ធ្លាប់ប្រាប់ទៅ ខឹម ងួន ថា ការសន្ទនានេះគឺ “មិនផ្លូវការ” ទេ ហើយការសន្ទនានេះមិនអាចប្រើជា“ផ្លូវការ” បានទេ ។

ខេល លីសាក់ មិនចាប់អារម្មណ៍អ៊ីដែល នួន ជា និយាយទេ ហើយគាត់បានអានអ៊ីដែលរៀបរាប់នៅក្នុងឯកសារនោះដែល នួន ជា ត្រូវបានស្រង់សម្តីមកថា អៀង សារី “គឺជាជនឆ្វេងនិយម ជាមនុស្សយ៉ាប់កែ និងងាកទៅរកឆ្វេងហើយ” ។ ក្រោយមក ខេល លីសាក់ បានសួរទៅ នួន ជា ថាអ៊ីទៅ គឺជា “ជនឆ្វេង” នោះ ។

ពេលនោះ ម៉ៃខល ផេសមិន មេធាវីរបស់ នួន ជា ជំទាស់ការស្រង់សម្តីចេញពីឯកសារនេះដោយបញ្ជាក់ថា ពេលនេះនៅតែមិនដឹងទេថាចំណុចនេះមានលក្ខណៈត្រឹមត្រូវទេថាកូនក្តីរបស់គាត់និយាយបែបនោះមែនឬអត់នោះទេ ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា គាត់សួរសំណួរនេះ ដើម្បីឲ្យដឹងថាតើសម្តីដែលគាត់ស្រង់នេះពិតឬអត់ ហើយការជំទាស់នេះគ្មានប្រសិទ្ធភាព ។

ខេល លីសាក់ បានសួរសំណួរទៅ នួន ជា ម្តងទៀត ហើយគាត់បានឆ្លើយតបថា សមាជិកបក្ស មានទាំងពួកឆ្វេងជង ស្តាំជង និងពួកអព្យាក្រឹតជង «ដូចខ្ញុំនេះជាដើម» ។ គាត់បានបញ្ជាក់ទៀតថា គាត់មិនដែលចាត់ទុក អៀង សារី ថាជាជនឆ្វេងនិយមម្តងណាទេ ហើយគាត់គឺជាសមាជិកបក្ស ។ «បើសិនជាពេលនោះ អៀង សារី គឺជាជនឆ្វេងមែននោះ យើងនឹងណែនាំគាត់ឲ្យមកដូចដើមវិញមិនខាន» ។

នៅពេលសួរថាតើគាត់មានដែលចាត់ទុក អៀង សារី ថាជាមនុស្ស«រឹងរូស និងកែមិនឡើងទេ» នួន ជា បានឆ្លើយថា សមាជិកបក្សមិនត្រូវនិយាយពី«កិច្ចការផ្ទៃក្នុង»របស់បក្ស ឬរិះគន់គ្នាទេ ។ សុន អរុណ មេធាវីរបស់ នួន ជា បានជំទាស់សំណួរនេះដោយនិយាយថា សហព្រះរាជអាជ្ញាកំពុងតែព្យាយាមឲ្យជនជាប់ចោទចង្អុលមុខដាក់គ្នាហើយ ។ ខេល លីសាក់ បានបដិសេធថា គាត់មិនមានគំនិតធ្វើបែបនេះទេ ហើយគាត់បានឆ្លើយតបទៅវិញថា គាត់គ្រាន់តែចង់សួរសំណួរអំពីអ្វីដែលមាននៅក្នុងឯកសារប៉ុណ្ណោះ ។ ជំទាស់នេះគ្មានប្រសិទ្ធភាព ។

ងាកទៅសួរអំពី ខឹម ងួន វិញ ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថា ហេតុអ្វីបានជាគាត់និយាយថា «ទូ សាមុត គឺជាមនុស្សគ្មានប្រយោជន៍ ព្រោះគាត់ចាស់ហើយមិនចេះដឹងច្រើនទៀត ។ ដូច្នេះមានតែខ្ញុំ និង សាឡុត ស ទេ» ។

មេធាវី ផេសមិន បានជំទាស់ដោយបញ្ជាក់ថា សំណួរនេះគឺចង់សន្និដ្ឋានថា នួន ជា ជាអ្នកសរសេរឯកសារនេះ ។ ខេល លីសាក់ បានអានសំណួរម្តងទៀតដើម្បីសួរទៅ នួន ជា ហើយ នួន ជា បានបដិសេធថា គាត់មិនមែនជាអ្នកសរសេរឯកសារនោះទេ ។ នួន ជា បានបញ្ជាក់ទៀតថា គាត់គោរព ទូ សាមុត ដែលកាលនោះគាត់ស្នាក់នៅវៀតណាមខាងត្បូង ហើយគាត់មិនអាចក្តាប់ស្ថានភាពនៅទីក្រុងភ្នំពេញបានទេ ។ ពេលសួរអំពីកិច្ចការរបស់គាត់ជាមួយ ទូ សាមុត នួន ជា បានឆ្លើយថា គាត់ ហើយ និង សាឡុត ស ទាក់ទងជាមួយមនុស្សចាស់ៗ«ដែលជាមនុស្សល្អ» ហើយចាប់ផ្តើមសាងទំនាក់ទំនងដើម្បីឲ្យអ្នកនោះអាចកសាងមូលដ្ឋាននៅក្នុងតំបន់របស់ខ្លួនបាន ។ នួន ជា បានរំឭកទៅតុលាការម្តងទៀតថា នេះគឺជាដំណាក់កាលយឺតៗ ដោយសារតែ«ពេលនោះចលាចលកំពុងកើតឡើង» ។

ពេលនោះ ចៅក្រម និល ណុន ប្រកាសសម្រាកអាហារថ្ងៃត្រង់ ។

## ការលើកឡើងទាក់ទងទៅនឹងទម្រង់ភ័ស្តុតាង

នៅពេលរសៀល ចៅក្រម និល ណុន បានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ថា សវនាការនេះ មិនបន្តនៅថ្ងៃស្អែកដែលជាថ្ងៃសុក្រទេ ហើយពេលនេះចៅក្រមកំពុងរៀបចំការវិភាគថាតើពេលណាគួរចាប់ផ្តើមសវនាការសម្រាប់ឆ្នាំក្រោយ ។

ពេលនោះ មេធាវីរបស់ ខៀវ សំផន ឈ្មោះ អាកទូរ វែកគែន បានក្រោកឈរហើយស្នើឲ្យតុលាការបញ្ជាក់ឲ្យច្បាស់ថា បញ្ហាអ្វីដែលត្រូវលើកមកនិយាយពេលដាក់ភស្តុតាង។ ដោយសម្អាងទៅលើសៀវភៅរបស់ ថេត សម្បត្តិ ដែលបានពិភាក្សាជាងពីរថ្ងៃមកហើយនោះ អាកទូរ វែកគែន បាននិយាយថា ចៅក្រម ខាតរ៉ាយថ៍ និយាយថា តុលាការនឹងសម្រេចអំពីការដាក់បញ្ចូលសៀវភៅនេះ។ សហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានឆ្លើយតបក្នុងនាមជាព្រះរាជអាជ្ញាដោយពន្យល់ថា ព្រះរាជអាជ្ញាយល់ថាការជជែកគ្នាថាគួរដាក់បញ្ចូលភស្តុតាងនេះនៅក្នុងតុលាការឬក៏អត់នោះ គួរតែយកមកពិភាក្សាថ្ងៃក្រោយ មិនមែននៅចំពោះមុខសាក្សីយ៉ាងនេះទេ ហើយធ្វើបែបនេះទើបដើម្បីកុំឲ្យមានការរំខានក្នុងការសួរសាក្សីផង។

អាកទូរ វែកគែន បានរក្សាជំហររបស់ខ្លួន ហើយគាត់លើកបញ្ហានេះឡើងព្រោះមេធាវីការពារក្តី "អាចមានអារម្មណ៍ថាជាកិច្ចការរបស់ខ្លួន" ដើម្បីប្រឆាំងទៅនឹងការដាក់បញ្ចូលឯកសារនេះដែលបានប្រគល់ជូនទៅសាក្សីដោយមិនគិតពីបញ្ហាជាមុន។ អាកទូរ វែកគែន បានស្នើថា បញ្ហានេះគួរតែដោះស្រាយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយគាត់បានទទូចថា បើសិនជាបញ្ហានេះដោះស្រាយបាន គឺអាចជួយគ្រប់ភាគីទាំងអស់"បានយ៉ាងច្រើន" ដើម្បីឲ្យដឹងពីជំហររបស់សវនាការនេះទាក់ទងនឹងបញ្ហានេះ។

ក្រោយពីចៅក្រមទាំងអស់ជជែកគ្នារួចមក ចៅក្រម ឡាវែន៍ ទទួលបានឱកាសដើម្បីបញ្ជាក់ពីបញ្ហានេះឲ្យបានច្បាស់។ ចៅក្រម ឡាវែន៍ និយាយថា តុលាការទទួលបានឯកសារ និងកំណត់ហេតុជាច្រើនដើម្បីស្នើឲ្យដាក់បញ្ចូល ហើយពេលនោះចៅក្រមបានជម្រាបទៅគ្រប់ភាគីទាំងអស់ថា អង្គសវនាការមានគម្រោងនឹងបើកសវនាការមួយនៅឆ្នាំក្រោយ ដោយពិភាក្សាគ្នាបញ្ហាទាក់ទងទៅនឹងឯកសារនិងភស្តុតាងតែប៉ុណ្ណោះ។ ពេលនោះ ភាគីទាំងអស់អាចបង្ហាញឯកសារនិងភស្តុតាងទាក់ទងនឹងបញ្ហានេះបាន។ ចៅក្រម ឡាវែន៍ បានរំឭកទៅគ្រប់ភាគីទាំងអស់ថា ជាការសំខាន់ណាស់ដែលយើងត្រូវបែកឲ្យដាច់រវាងការដាក់បញ្ចូលឯកសារ និងការវាយតម្លៃពីតម្លៃរបស់ឯកសារនោះ។

មេធាវី អាកទូរ វែកគែន បាននិយាយទៀតថា បញ្ហានេះ "មានលក្ខណៈស្រពេចស្រពិលបន្តិច" អំពីថាតើឯកសារពិតអាចដាក់បញ្ចូលចំពោះមុខតុលាការដោយស្វ័យប្រវត្តិដែរឬទេ តែពេលនេះគ្រប់ភាគីទាំងអស់អាចពិភាក្សាគ្នាមុននឹងដាក់បញ្ចូលឯកសារអ្វីមួយ។ ចៅក្រម ឡាវែន៍ បាននិយាយកាត់មេធាវី អាកទូរ វែកគែន ដោយសារតែអ្វីដែលមេធាវីនិយាយអាចមានការភាន់ច្រឡំ។ ចៅក្រម ឡាវែន៍ បានបញ្ជាក់សាឡើងវិញថា តុលាការធ្លាប់ជម្រាបប្រាប់គ្រប់ភាគីទាំងអស់ហើយថា ឯកសារដែលបានរៀបរាប់នៅក្នុងលេខយោងអាចយកមកប្រើប្រាស់ដាក់បញ្ចូលនៅក្នុងតុលាការបាន ល្គឹកណាភាគីដែលដាក់នោះមិនមានការជំទាស់អ្វីទេ។

មេធាវី អាកទួរ វែកគែន បានបញ្ជាក់បន្ថែមទៀតថា ទីបញ្ចប់គាត់យល់ហើយ ហើយគាត់បានតបថា អ្វីដែលគាត់បារម្ភនោះគឺថា ឯកសារយ៉ាងច្រើនទាំងនេះដែលដាក់នៅក្នុងដីកាដំណោះស្រាយមិនមានការបកប្រែជាភាសាទាំងបីរបស់តុលាការនៅឡើយទេ ហើយគាត់ជួបប្រទះនូវបញ្ហាខ្វះក្នុងការសម្រេចថាតើត្រូវដាក់ឯកសារនោះបញ្ចូលឬអត់ ។ អាកទួរ វែកគែន បានសួរថាតើនេះអាចជាបញ្ហានៅថ្ងៃក្រោយដែរឬទេ ។

ចៅក្រម និល ណុន បានព្យាយាមបិទការពិភាក្សាពីបញ្ហានេះដោយបញ្ជាក់ថា មានបញ្ហាពីរ ទីមួយគឺថាតើឯកសារមួយណាដែលត្រូវដាក់បង្ហាញនៅចំពោះមុខសវនាការដែលបានដោះស្រាយរួចហើយ ហើយទីពីគឺថា បញ្ហាបកប្រែកំពុងតែធ្វើហើយ ។ ចៅក្រម និល ណុន បានបញ្ជាក់ថា បញ្ហាទីមួយត្រូវបានលើកយកមកនិយាយច្រើនលើកច្រើនសាមកហើយ ហើយគាត់ស្នើទៅគ្រប់ភាគីទាំងអស់ឲ្យលើកយកមកបញ្ហានេះមកនិយាយពេលក្រោយវិញ ។

មេធាវី អាកទួរ វែកគែន មិនពេញចិត្តនូវអ្វីដែលចៅក្រមនិយាយទេ ហើយគាត់បញ្ជាក់ទៀតថាអនុស្សារណៈនោះដាក់បន្ទុកលើគ្រប់ភាគីទាំងអស់ដើម្បីបកប្រែឯកសារទាំងអស់នោះដែលខ្លួនចង់ប្រើ ហើយកិច្ចការនេះគួរតែធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតចំពោះឯកសារណា ដែលមាននៅក្នុងដីកាដំណោះស្រាយ ។ អាកទួរ វែកគែន បាននិយាយថា «ពេលដែលខ្ញុំឮថា បញ្ហានេះត្រូវបានដោះស្រាយហើយនោះ ខ្ញុំមិនយល់ស្របទេ» ហើយបញ្ហានេះត្រូវតែឲ្យសាធារណជនដឹងឮដើម្បីឲ្យគេដឹងពីផលលំបាក ដែលភាគីទាំងអស់កំពុងតែជួបប្រទះ ។

ចៅក្រម និល ណុន បានឆ្លើយតបទៅវិញថា គាត់និយាយថា មានបញ្ហាពីរ ហើយបញ្ហាទីមួយត្រូវបានដោះស្រាយរួចហើយ ចំណែកឯបញ្ហាបកប្រែកំពុងតែពិចារណារ ។ ពេល អាកទួរ វែកគែន រៀបនិយាយ ចៅក្រម និល ណុន បានប្រកាសដោយសម្ដីឮៗថា «លោកមិនបាច់និយាយអ្វីទៀតទេ» ។ ពេលនោះ ចៅក្រម ឡាវ៉ែន់ បាននិយាយកាត់ថា «សូមដោះស្រាយបញ្ហាដោយសន្តិវិធី» ហើយគាត់បានប្រាប់ទៅមេធាវី អាកទួរ វែកគែន ថា អង្គសវនាការបានចេញប្រកាសអនុស្សារណៈជាច្រើនមកហើយអំពីបញ្ហានេះមុននឹងលោកក្លាយជាមេធាវីរបស់ ខៀវ សំផន ទៅទៀត ហើយចៅក្រមបានប្រាប់ទៅមេធាវីនោះឲ្យអានសេចក្ដីប្រកាសនោះឡើងវិញ ។

## ការពិភាក្សាលើសក្ខីកម្ម និងភ័ស្តុតាងរបស់ នួន ជា បន្តទៀត

ខេល លីសាក់ បានចាប់ផ្ដើមសួរសំណួរបន្តទៀតទៅកាន់ នួន ជា ដោយនិយាយពីប្រធានបទ «ទង់បដិវត្តន៍កិត្តិយស»វិញ ដែលគាត់បានអះអាងថា គាត់បានប្រគល់ទង់កិត្តិយសទៅស្រុកចំនួនបីក្នុងឆ្នាំ ១៩៧៦ ។ ក្រោយពី នួន ជា បញ្ជាក់ថា គាត់មិនចាំហេតុការណ៍ទាំងនោះទេ ព្រះរាជអាជ្ញាបានបង្ហាញ

ឯកសារដែលមានចំណងជើងថា «លិខិតជូនទង់ក្រហមកិត្តិយសរបស់កម្ពុជាប្រជាធិបតេយ្យ» ហើយគាត់បានប្រគល់ឯកសារនោះទៅ នួន ជា ដែរ ។ នួន ជា បានបញ្ជាក់ថា គាត់អានឯកសារនេះមិនដាច់ទេ ព្រោះអក្សរតូចៗពេក ហើយងងឹតផង ។ តែគាត់និយាយថា បើសិនជាស្រុកនោះ«ដំណើរការល្អ» ស្រុកនោះនឹងទទួលបានទង់ក្រហមកិត្តិយស ។ នៅពេលសួរថាតើទង់នោះមានសារសំខាន់អ្វីទៅ នួន ជា បានឆ្លើយថា ទង់ក្រហមកិត្តិយស ត្រូវបានប្រគល់ជូនសាខាបក្សដែលបានសម្រេច«សមិទ្ធផលដើម្បីជីវភាពប្រជាជន» ឬដែល«បានធ្វើកិច្ចការល្អសម្រាប់បក្ស» ។ ទង់ក្រហមកិត្តិយស ក៏ត្រូវប្រគល់ជូនតាមសំណើរបស់ភូមិភាគដែរ តែទង់នេះផ្តល់ចំពោះតែ«កិច្ចការល្អដែលបានធ្វើ» ដែលមានន័យថា សាខាបក្សត្រូវធ្វើកិច្ចការច្រើនដើម្បីទទួលបានទង់កិត្តិយស ។

ទាក់ទងទៅនឹងការអប់រំនយោបាយ ខេល លីសាក់ បានសួរថា នៅពេលណាទើប នួន ជា ទទួលភារកិច្ចខាងអប់រំនយោបាយដល់សមាជិកបក្ស ។ នួន ជា បានឆ្លើយថា ក្រោយពីសន្និសីទក្រុងហ្សឺណែវ គាត់ទទួលភារកិច្ចតែមួយប៉ុណ្ណោះ គឺអប់រំបណ្តុះបណ្តាលដល់សមាជិកបក្ស ។ ក្រោយពីសន្និសីទនោះ នៅពេលដែលយោធាទាំងអស់ត្រូវបានរំលាយខ្លួន ពេលនោះ«មានការលំបាកណាស់សម្រាប់ប្រជាជនគ្រប់រូបដើម្បីត្រូវរួំវគ្នា» ។ យោធាត្រូវតែរួមបញ្ចូលគ្នាចូលទៅក្នុង«សង្គមញៀស្រី ពុករលួយ» ដែលបង្កឲ្យមានជម្លោះ ។ នួន ជា បានបញ្ជាក់ទៀតថា នេះគឺជាកិច្ចការដ៏លំបាកមួយ ជាពិសេសតាំងពី«ប្រពន្ធរបស់កម្មាភិបាលបានព្យាយាមបញ្ចុះបញ្ចូលកម្មាភិបាលទាំងនោះឲ្យលះបង់សកម្មភាពមិនល្អ និងកិច្ចការណាមិនល្អ» ។ នួន ជា បានរំឭកទៀតថា នៅក្នុងសង្គមនេះ មានតែសាខាបក្សពីរកន្លែងប៉ុណ្ណោះដែលនៅមានសកម្មភាពខ្លាំង ហើយសាខាផ្សេងទៀត គឺជាសាខាពុករលួយ ។ នួន ជា បញ្ជាក់ថា «សមរភូមិតម្រូវឲ្យទាក់ទងគ្នាយ៉ាងស្អិតរមួត ។ យើងធ្វើកិច្ចការទាំងអស់ដែលត្រូវធ្វើ» ។

សហព្រះរាជអាជ្ញាចាប់ផ្តើមសួរអំពីទស្សនាវដ្តីទង់បដិវត្តន៍ ហើយបានសួរទៅជនជាប់ចោទថា មានដែលប្រើប្រាស់ទស្សនាវដ្តីនោះក្នុងគោលបំណងអប់រំដែរឬទេ ។ នួន ជា បានឆ្លើយថា ទស្សនាវដ្តីនោះមិនចែកជូនគ្រប់កម្មាភិបាលទាំងអស់ទេ ហើយកម្មាភិបាលខ្លះ «ខ្ជិល និងមិនចង់អប់រំខ្លួនឯងផង ហើយចង់រស់នៅដោយខ្លួនឯង» ។ ទស្សនាវដ្តីនោះត្រូវបានចែកផ្សាយដល់កម្មាភិបាលភូមិភាគដែលជាអ្នកធានាថា កម្មាភិបាលថ្នាក់ក្រោមទៀតទទួលបានទស្សនាវដ្តីនោះ ។ នួន ជា បាននិយាយទៀតថា ទង់បដិវត្តន៍ គឺជាផ្នែកមួយនៃការអប់រំនយោបាយដូចឯកសារផ្សេងទៀតដែរ ហើយគណៈអចិន្ត្រៃយ៍ជាអ្នក«បោះពុម្ព»ទស្សនាវដ្តីនោះ ហើយថា គាត់ និង ប៉ុល ពត «ជាអ្នកសរសេរទស្សនាវដ្តីនោះ» ។

ដោយលើកយកទស្សនាដ្តីទង់បដិវត្តន៍ចុះខែកញ្ញា ឆ្នាំ១៩៧៧ ដែលចៅក្រម ខាតរ៉ាយថ៍ ធ្លាប់បង្ហាញនៅចំពោះមុខតុលាការម្តងហើយកាលពីពីរថ្ងៃមុន ខេល លីសាក់ បានអានប្រសាសន៍របស់ ប៉ុល

ពត នៅក្នុងទស្សនាវដ្ដីនោះដែលនិយាយថា «ស្មារតីមេដឹកនាំរបស់វណ្ណៈកេងប្រវ័ញ្ច» ។ នៅពេលសួរថាតើនេះសំដៅទៅលើព្រះសង្ឃ ពុទ្ធសាសនាមែនទេ នួន ជា បានឆ្លើយថា តើគាត់សុំអានឯកសារនោះមុនសិនបានទេ ។ មន្ត្រីតុលាការបានប្រគល់ឯកសារនោះទៅជនជាប់ចោទ ដែលបង្កឲ្យមានការជំទាស់ពីជនជាប់ចោទ ហើយជនជាប់ចោទបានបដិសេធនូវអ្វីដែលបានសរសេរនៅក្នុងទស្សនាវដ្ដីនោះស្ទើរពេញមួយថ្ងៃ ។

ក្រោយពីទទួលបានឯកសារហើយ នួន ជា បាននិយាយថា «ទង់បដិវត្តន៍មិនមែនបោះពុម្ពក្នុងទំហំក្រដាសនេះទេ» ។ ទង់បដិវត្តន៍ គឺជាសៀវភៅ» ។ នួន ជា បាននិយាយទៀតថា «ឯកសារបែបហ្នឹងនរណាក៏អាចបន្លំបានដែរ» ។

ខៀល លីសាក់ បានជំទាស់ ហើយបញ្ជាក់ថា ឯកសារនេះគឺជាសុន្ទរកថារបស់ ប៉ុល ពត នៅថ្ងៃខួបកំណើតលើកទី១៧របស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្រោយមក ខៀល លីសាក់ បានឲ្យ នួន ជា មើលឯកសារនោះឲ្យជិត ។ ជនជាប់ចោទបានឆ្លើយតបដោយខឹងថា «ខ្ញុំនិយាយហើយនិយាយទៀតថា ឲ្យឯកសារនោះមកខ្ញុំមក» ។ សុន អរុណ មេធាវីរបស់ នួន ជា បានគាំទ្រការជំទាស់របស់ នួន ជា ហើយគាត់ស្នើឲ្យប្រគល់ឯកសារដើមទៅកូនក្ដីរបស់គាត់ ។

សហព្រះរាជអាជ្ញាបានរំឭកទៅ នួន ជា និង សុន អរុណ ថា ចៅក្រម ខាត់រ៉ាយច៍ បានដាក់ឯកសារនេះកាលពីពីរថ្ងៃមុនរួចហើយ ហើយកាលនោះមិនមានភាគីណាមួយជំទាស់ទេ ។ ខៀល លីសាក់ បានងាកមកមើលចៅក្រម ហើយសួរបន្តទៀត ដោយស្នើទៅចៅក្រមឲ្យជម្រាបទៅជនជាប់ចោទឲ្យឆ្លើយសំណួរ ។

ចៅក្រម និល ណុន បាននិយាយទៅជនជាប់ចោទថា ជាទូទៅឯកសារដែលដាក់បង្ហាញនៅចំពោះមុខតុលាការត្រូវបំលែងទៅជាឯកសារនៅក្នុងកុំព្យូទ័រ ដើម្បីឲ្យឯកសារជាច្រើនសន្លឹកសន្ធាប់ទាំងនេះដែលមានប្រហែលជាប្រាំសែនឯកសារអាចគ្រប់គ្រងបាន ។ ចៅក្រមបានយល់ស្របជាមួយព្រះរាជអាជ្ញា ហើយគាត់បានជំទាស់ថា កាលនោះគ្មានភាគីណាមួយបដិសេធទេនៅពេលដែលចៅក្រម ខាត់រ៉ាយច៍ បង្ហាញឯកសារដើមកាលពីពីរថ្ងៃមុន ។

មេធាវី សុន អរុណ នៅមិនសុខ ហើយនិយាយកាត់ចៅក្រមថា «លោកនិយាយអ៊ីចឹងចេះតែបានហើយ តែនេះជារឿងសំខាន់ណាស់» ។ សុន អរុណ បាននិយាយទៀតថា ឯកសារដើមគួរតែយកមកបង្ហាញ «ដើម្បីឲ្យកូនក្ដីរបស់គាត់ទុកចិត្ត» ។

ចៅក្រម និល ណុន ហាក់បីដូចជាខឹងមេធាវី សុន អរុណ ដែរ ហើយបាននិយាយថា នួន ជា គួរតែលើកឡើងពីបញ្ហានេះពេលទទួលបានដីកាដំណោះស្រាយ ។

ក្រោយមក នួន ជា និយាយទៀតថា គាត់ចង់ឃើញឯកសារដើម ។ គាត់និយាយទៀតថា ទាល់តែគាត់ទទួលបានឯកសារដើមទើបគាត់អាចនិយាយបានថា តុលាការ«កំពុងតែស្វែងរកការពិតនិងយុត្តិធម៌ ហើយមិនមែនជាតុលាការក្លែងក្លាយ» ។ នួន ជា បាននិយាយឮៗទៀតថា «បើមិនប្រគល់ឯកសារដើមមកខ្ញុំទេ ខ្ញុំមិនទទួលស្គាល់ឯកសារនេះទេ ។ ខ្ញុំសូមបដិសេធ» ។

ក្រោយពី នួន ជា ទទូចបែបនេះ ចៅក្រមពិភាក្សាគ្នា ហើយសិស្សដែលកំពុងអង្គុយមើលក៏និយាយជាមួយគ្នាដែរ ។ ក្រោយមក ចៅក្រម និល ណុន បានជូនដំណឹងទៅភាគី នួន ជា ថា ឯកសារត្រូវបានដាក់នៅក្នុងសំណុំរឿងរួចហើយ ហើយបានយកមកនិយាយគ្រប់ពេលនៃដំណើរការសវនាការទាំងអស់ ។ ចៅក្រម និល ណុន បាននិយាយថា ក្រោយពីឯកសារត្រូវបានដាក់នៅក្នុងសំណុំរឿងរួចហើយ ឯកសារនោះ គឺមានសុពលភាពហើយ ។

នួន ជា បានគោះម្រាមដៃនៅលើតុរបស់គាត់ ហើយបាននិយាយកាត់ថា «ឯកសារនេះមិនមែនជាឯកសារទង់បដិវត្តន៍ទេ» ។

មេធាវី ម៉ៃខល ផេសមិន ក៏គាំទ្រកូនក្តីរបស់ខ្លួនដែរ ដែលបញ្ជាក់ថា បញ្ហានៅពេលនេះគឺថា មិនមែនចង់ដឹងថាឯកសារត្រូវបានដាក់បង្ហាញនៅចំពោះមុខតុលាការពីមុនឬយ៉ាងណាទេ តែបញ្ហាសំខាន់គឺថា តើឯកសារនេះមានការពិតយ៉ាងណា ។ មេធាវី ម៉ៃខល ផេសមិន បាននិយាយថា «នេះគឺមានហេតុផលសមរម្យហើយ» ដែលកូនក្តីរបស់ខ្លួនសុំមើលឯកសារដើមនោះ ។ មេធាវី ម៉ៃខល ផេសមិន បាននិយាយថា «ឯកសារនោះពិតជានៅកន្លែងណាមួយមិនខាន» ។

ក្រោយមកចៅក្រម និល ណុន បានប្រាប់ទៅមន្ត្រីតុលាការឲ្យចុចបង្ហាញឯកសារនោះចុះក្រោមយឺតៗដើម្បីឲ្យជនជាប់ចោទមើលឯកសារនោះពេញ ។ ពេលនោះ សហព្រះរាជអាជ្ញាបានសុំទៅចៅក្រមសួរសំណួរទៅជនជាប់ចោទនូវសំណួរទូទៅ ។ ចៅក្រមអនុញ្ញាត ។ ពេលនោះ ឌុល លីសាក់ បានចាប់ផ្តើមសួរអំពីសាសនា ។ ព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា នួន ជា តែងសម្តែងគារវកិច្ចចំពោះ«ព្រះសង្ឃ»រៀងរាល់ថ្ងៃមុននឹងគាត់ឡើងនិយាយ ហើយតើ នួន ជា ធ្វើបែបនេះដែរឬទេមុននឹងឡើងនិយាយកាលពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ឌុល លីសាក់ បានបញ្ជាក់ទៀតថា តើករណីនេះយ៉ាងម៉េចដែរ ។

ជនជាប់ចោទ នួន ជា បានឆ្លើយតបថា ក្នុងន័យថា «សុន្ទរកថាគឺជារឿងនយោបាយ» ហើយថាគាត់មិនចង់លាយឡំគ្នារវាងនយោបាយនិងសាសនាទេ «បើសិនជាលោកយកព្រះសង្ឃមកលាយឡំគ្នានោះនឹងមានការភាន់ច្រឡំមិនខាន» ។ នួន ជា បានបន្តទៀតថា ការបែងចែកគ្នានេះមិនមានន័យថា បក្សកុម្មុយនីស្តកម្ពុជាបដិសេធព្រះសង្ឃទេ «អ្នកដែលនិយាយថាយើងបំផ្លាញព្រះសង្ឃនោះ អ្នកនោះមិនយល់ពីធាតុពិតរបស់ពុទ្ធសាសនាទេ» ។ ក្រោយមក នួន ជា ចាប់ផ្តើមនិយាយពីលោកនេនពុទ្ធសាសនា ដែលត្រូវ

គោរពគោលការណ៍ពុទ្ធសាសនាជាប់ជានិច្ច ។ ពេលនិយាយបែបនេះ អ្នកចូលរួមដែលក្នុងនោះ ក៏មានព្រះសង្ឃមានការភ្ញាក់ផ្អើលដែរ ។

ក្រោយមក ចៅក្រម និល ណុន ប្រកាសសម្រាក ។

## ការបដិសេធនឹងភ័ស្តុតាងថតចម្លងបន្តរហូតដល់ចប់

ក្រោយពីតុលាការត្រឡប់មកពីសម្រាកវិញ មេធាវីរបស់ ខៀវ សំផន ឈ្មោះ អាកទួរ វែកគែន បានលើកពីបញ្ហានេះម្តងទៀតទាក់ទងទៅនឹងបញ្ហាភ័ស្តុតាងថតចម្លង ដោយសារបញ្ហានេះគឺ“ជាក្តីបារម្ភរបស់យើងទាំងអស់គ្នា” ។ មេធាវី អាកទួរ វែកគែន បានទាញចំណាប់អារម្មណ៍ទៅនឹងសវនាការ ឌុច កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ដែលពេលនោះតុលាការបានធ្វើសេចក្តីសម្រេចរួចហើយ ។ មេធាវី អាកទួរ វែកគែន បាននិយាយដោយឆ្លើយតបការពិភាក្សាទាក់ទងទៅនឹងការបកប្រែភាសាថា អនុស្សារណៈរបស់តុលាការកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ បាន“សរសេរច្បាស់”ហើយថា គ្រប់ភាគីទាំងអស់ដែលចង់ប្រើប្រាស់ឯកសារដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយគឺ “មានតួនាទី”ស្នើសុំឯកសារនោះទៅបកប្រែ បើមិនដូច្នេះទេ ភាគីនោះមិនមានលទ្ធភាពប្រើប្រាស់ឯកសារនោះទេ។ មេធាវី អាកទួរ វែកគែន បានជំទាស់ការដាក់បន្ទុកនេះចំពោះភាគីទាំងអស់ ។

សហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានឆ្លើយតបទៅនឹងសម្តីរបស់មេធាវី អាកទួរ វែកគែន ដោយរំឭកថា ច្បាប់ទាក់ទងនឹងការបង្ហាញឯកសារត្រូវបានអនុម័តដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីសេចក្តីសម្រេចឆ្នាំ២០០៩មកម្ល៉េះ ហើយគ្រប់ភាគីទាំងអស់ត្រូវតម្រូវឲ្យបង្ហាញនិងជំទាស់ឯកសារដែលមានជាលាយលក្ខណ៍អក្សរនោះ ។ ទាក់ទងទៅនឹងឯកសារថតចម្លងនោះ វីល្លៀម ស្មីត បានអះអាងថា គ្រប់ភាគីទាំងអស់គួរតែមានហេតុផលឲ្យបានច្រើនដើម្បីជំទាស់ ជាជាងគ្រាន់តែយកហេតុផលតូចតាចបែបនេះ ។ ក្រោយមក វីល្លៀម ស្មីត បានជូនដំណឹងទៅតុលាការថា ការប្រើប្រាស់ឯកសារថតចម្លងនេះ គឺអាចទទួលយកបានគ្រប់តុលាការអន្តរជាតិទាំងអស់ ដោយសារតែចំនួនឯកសារមានច្រើនពេក មិនអាចយកឯកសារដើមមកបង្ហាញទាំងអស់បានទេ ហើយតុលាការអន្តរជាតិ គឺធ្វើការបែបនេះ ។ វីល្លៀម ស្មីត បានបញ្ចប់សេចក្តីថា ភាគីការពារក្តីបានចំណាយពេលច្រើនពេក ដើម្បីជំទាស់ឯកសារទាំងនោះ ហើយថា “បើសិនជាភាគីការពារក្តីមានការជំទាស់ប្រសើរជាងនេះ គួរតែលើកមកនិយាយនៅសវនាការណាមួយដែលនិយាយពីបញ្ហានេះប៉ុណ្ណោះ” ។

មេធាវី ម៉ៃខល ផេសមិន បានក្រោកឈរ តែត្រូវបន្ទោសដោយចៅក្រមដោយសារមិនបានសុំចៅក្រមជាមុន។ មេធាវី ម៉ៃខល ផេសមិន បានសួរថា “តើខ្ញុំសួរដោយមិនក្រោកឈរ និងចុចកុងតាក់ម៉ៃចនឹងកើត? នេះគឺជាសំណួរសំខាន់” ។ ចៅក្រម និល ណុន ដោយការខឹងមិនបានឆ្លើយតបទៅនឹង

សំណួរនេះទេ តែបានប្រាប់ទៅមេធាវី ម៉ៃខល ផេសមិន ថា អាចនិយាយបាន។ ក្រោយមក មេធាវី ម៉ៃខល ផេសមិន បានបញ្ជាក់ថា ក្រុមមេធាវីរបស់ នួន ជា ស្នើឲ្យមានការបង្កើតទម្រង់មួយ ដើម្បីដោះស្រាយជាមួយភាពពិតរបស់ឯកសារ ហើយថា ភាគីរបស់ នួន ជា បានលើកយកបញ្ហានេះមកនិយាយច្រើនលើកច្រើនសាមកហើយ មិនមែនទើបតែថ្ងៃនេះទេ។ ក្រោយមក មេធាវី ម៉ៃខល ផេសមិន បានស្នើឲ្យមានសវនាការជជែកពីរឿងនេះ «ចំនួនមួយសប្តាហ៍» ទាក់ទងទៅនឹងបញ្ហាភ័ស្តុតាងនេះ។

ចៅក្រម និល ណុន បានឡើងនិយាយបញ្ចប់ដោយបញ្ជាក់ថា អង្គសវនាការមិនពិចារណាទាក់ទងនឹងបញ្ហានេះទេ ហើយក្រោយមកចៅក្រមបានប្រាប់សហព្រះរាជអាជ្ញាឲ្យបន្តសំណួរទៅមុខទៀត បើសិនជាមានសំណួរណាមិនទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្តន៍។

ខេល លីសាក់ បានបញ្ជាក់ថា គាត់មានសំណួរមួយទៀតទាក់ទងនឹងសាសនា។ គាត់បានសួរទៅ នួន ជា ថាតើត្រឹមត្រូវឬទេដែលបក្សបានហាមប្រាមពុទ្ធសាសនា និងផ្សឹកលោកសង្ឃនោះ។ នួន ជា បានឆ្លើយតបថា «បក្សមិនមានវិធានការហាមប្រាមពុទ្ធសាសនាទេ» ។ នៅពេលសួរថាតើបក្សដោះស្រាយទៅនឹងគោលការណ៍របស់ពុទ្ធសាសនាយ៉ាងណា ដូចជាកម្មពៀរ ដែល«មិនដើរស្របគ្នា»ជាមួយបក្សនោះ នួន ជា បានឆ្លើយថា កម្មពៀរមិនមែនមិនដើរស្របគ្នាជាមួយគោលការណ៍កុម្មុយនីស្តទេ ហើយបក្សក៏មិនដែលធ្វើកិច្ចការណាមួយប្រឆាំងនឹងសាសនាដែរ ។

ក្រោយមក សហព្រះរាជអាជ្ញាបានឲ្យ នួន ជា ឆ្លើយទៅនឹង«សាក្សីរាប់ពាន់នាក់» ដែលបាននិយាយនៅក្នុងសំណុំឯកសារ ដែល«ទាំងអស់គ្នា» និយាយថា បក្សបានបិទវត្តអារាម ផ្សឹកព្រះសង្ឃ និងហាមប្រាមមិនឲ្យមានការគោរពពុទ្ធសាសនា។ មេធាវី ម៉ៃខល ផេសមិន ជំទាស់សំណួរនេះ ដោយបញ្ជាក់ថា គាត់«មិនស្គាល់សាក្សីរាប់ពាន់នាក់នេះទេ» ហើយទាក់ទងទៅនឹងសំណួរនេះ ដែលលើកមកសួរនាសវនាការនេះមិនមានភាពច្បាស់លាស់ទេ។

ខេល លីសាក់ បានអះអាងថា វាច្បាស់ណាស់នៅក្នុងសំណុំរឿងដែលថា បក្សបានសម្រេចហាមប្រាមពុទ្ធសាសនាមុនឆ្នាំ១៩៧៥ ហើយថា «សំណួរនេះ គឺកើតឡើងពិតចំពោះសាក្សី» ។

មេធាវី កាណាវ៉ាស របស់ អៀង សារី បានស្នើសុំចូលរួមយោបល់ដោយនិយាយថា «ខ្ញុំមិនចង់បែករំលែកពីការពិតដែលសហព្រះរាជអាជ្ញាបាននិយាយទេ» ហើយគាត់បានទទូចថា ព្រះរាជអាជ្ញាត្រូវតែបង្ហាញសម្តីនេះឲ្យបានច្បាស់ចំពោះសាក្សីណាដែលបាននិយាយបែបនេះ ហើយមិនត្រូវយកសម្តីបែបនេះមកនិយាយពី«ការពិត»ទេ។ មេធាវី កាណាវ៉ាស បានកត់សម្គាល់ឃើញថា សំណួរនេះហួសពីព្រំដែនដែលត្រូវកំណត់ឲ្យសួរហើយសម្រាប់ដំណាក់កាលសវនាការនេះ។ មេធាវី កាណាវ៉ាស បានជំទាស់រក្សា

ជំហររបស់ខ្លួនថា «យើងមិនជំទាស់ទេ ដរាបណាយើងដឹងពីរូបវន្តទាំងនេះ» តែអ្វីដែលព្រះរាជអាជ្ញាបាន ឆ្លើយតបដោយបញ្ជាក់ពីការពិតនោះ គឺមិនពាក់ព័ន្ធទៅនឹងសវនាការថ្ងៃនេះទេ។

ចៅក្រម និល ណុន គាំទ្រការជំទាស់នេះ ដោយសារតែការគាបសង្កត់ផ្នែកសាសនាមិនត្រូវយក មកសួរនាំនាដំណាក់កាលនេះទេ។ ក្រោយពីបន្ទោសសហព្រះរាជអាជ្ញា ឲ្យសួរពាក់ព័ន្ធតែនឹងដំណាក់កាល ដែលត្រូវសួររួចហើយ ចៅក្រម និល ណុន បានប្រាប់ទៅព្រះរាជអាជ្ញាឲ្យបន្តសំណួរទៀត។

ខេល លីសាក់ បានបញ្ជាក់ថា សំណួរដែលគាត់សួរពាក់ព័ន្ធទៅនឹងសវនាការនេះ ដោយសារតែ សំណួរនេះដកស្រង់ចេញពីសម្ដីរបស់ ប៉ុល ពត អំពីស្ថានភាពសង្គមកម្ពុជាក្នុងឆ្នាំ១៩៦០ ដែលកាលនោះ សង្គមបានចាត់ទុកសាសនាជាសត្រូវ។ មេធាវី កាណាវ៉ាស បានជំទាស់ម្ដងទៀតដោយបញ្ជាក់ថា សហ ព្រះរាជអាជ្ញា «កំពុងតែធ្វើសក្ខីកម្ម» និង«កំពុងតែព្យាយាមបង្កើតភ័ស្តុតាងតាមគំនិតរបស់ខ្លួនហើយ»។ ចៅក្រម និល ណុន បន្ទោស និងខឹងព្រះរាជអាជ្ញា «បញ្ហានេះវាខុស ហើយសំណួរដែលសួរមិនស្ថិតក្នុង ដំណាក់កាលសវនាការនេះទេ»។

ខេល លីសាក បានត្រឡប់ទៅសួរជនជាប់ចោទវិញដោយសួរថាតើគាត់មានចាំអ្វីដែល ប៉ុល ពត និយាយក្នុងឆ្នាំ១៩៧៧ដែលពេលនោះ ប៉ុល ពត បានប្រកាសអំពីការបង្កើតបក្សកុម្មុយនីស្តដែរឬទេ។ នួន ជា បានឆ្លើយក្នុងន័យធុញទ្រាន់ថា «បើលោកមានឯកសារ សូមយកមកបង្ហាញខ្ញុំឥឡូវនេះមក»។

ខេល លីសាក់ បានជូនដំណឹងទៅ នួន ជា ថា ឯកសារស្រដៀងគ្នានេះត្រូវបានយកមកពិភាក្សា ពេញមួយរសៀល ហើយជនជាប់ចោទក៏បានអានសុន្ទរកថា និងបានផ្ដល់ជូនលេខកូដឯកសារទៅតុលាការ ហើយដែរ។ ពេលដែលមន្ត្រីតុលាការដាក់ឯកសារដើម្បីបញ្ចាំងនៅលើអេក្រង់របស់តុលាការ ខេល លី-សាក់ បានសួរម្ដងទៀតថាតើជនជាប់ចោទមានចាំពីសុន្ទរកថារបស់ ប៉ុល ពត ទេ។ នួន ជា បាននិយាយ ដោយសម្ដីស៊ីកសៀតថា «នេះគឺជាឯកសារទង់បដិវត្តន៍ដែលខ្ញុំបដិសេធរួចហើយ។ នៅក្នុងទង់បដិវត្តន៍ មិន មានខ្លឹមសារណានិយាយពីពុទ្ធសាសនាទេ ហើយឥឡូវនេះ លោកនៅតែឲ្យឯកសារនេះមកខ្ញុំដដែល»។

សហព្រះរាជអាជ្ញាបានសួរសំណួរម្ដងទៀតថា «តើលោកមានចាំសម្ដីរបស់ ប៉ុល ពត ទេ»។ ជន ជាប់ចោទបានឆ្លើយតបវិញថា គាត់មិនចាំសម្ដីនេះទេ។ ក្រោយមក ខេល លីសាក់ បាននិយាយថា «បើ លោកមិនចាំសម្ដីរបស់ ប៉ុល ពត ហេតុអ្វីបានជាលោកនិយាយថា នេះមិនមែនជាសម្ដីពិត»។ នួន ជា បានឆ្លើយទៅវិញថា គាត់មិនយល់សំណួរទេ។

ដោយសារតែបញ្ហាទស្សនាវដ្ដីទង់បដិវត្តន៍លើកយកមកនិយាយម្ដងទៀត ចៅក្រម និល ណុន បានបង្គាប់ឲ្យមន្ត្រីតុលាការចុះឯកសារនេះយឺតៗ ដើម្បីឲ្យ នួន ជា អាចមើលឃើញជិតបាន។ ក្រោយ

ពីមើលឃើញឯកសារទាំងមូលហើយ ចៅក្រម និល ណុន បានស្នើឲ្យព្រះរាជអាជ្ញាសួរសំណួរម្តងទៀតយឺតៗ ។

សហព្រះរាជអាជ្ញាបានសួរសំណួរនេះដដែល ។ ចៅក្រម និល ណុន បានប្រាប់ទៅព្រះរាជអាជ្ញាម្តងទៀតក្នុងន័យខឹងថា «លោកសួរសំណួរដដែលៗ ហើយបញ្ហានៅតែកើតមានដដែលៗ» ។ ដូច្នេះ តុលាការសម្រេចបង្ហាញឯកសារទាំងមូលទៅជនជាប់ចោទ ។

មកដល់ចំណុចនេះ នួន ជា បានលើកដៃ ហើយតុលាការអនុញ្ញាតឲ្យគាត់និយាយ ។ នួន ជា និយាយថា «ខ្ញុំសូមជម្រាបម្តងទៀតថា ខ្ញុំមិនទទួលស្គាល់ឯកសារទង់បដិវត្តន៍នេះទេ ។ ទោះបីយកមកបង្ហាញខ្ញុំ ក៏ខ្ញុំមិនទទួលស្គាល់ដែរ ។ ឲ្យខ្ញុំទទួលស្គាល់យ៉ាងម៉េច? បើខ្ញុំមិនដឹងអ្វីផង» ។

ចៅក្រម និល ណុន បានថ្លែងអំណរគុណទៅជនជាប់ចោទដែលបានបញ្ជាក់យ៉ាងច្បាស់ ហើយចៅក្រមបានបញ្ជាក់ថា ពេលនេះដល់ពេលបញ្ចប់សវនាការសម្រាប់ថ្ងៃនេះហើយ ។ មុននឹងបញ្ចប់ មេធាវីរបស់ នួន ជា ឈ្មោះ អេនទ្រូ អ៊ីនូហ្ស៊ី បានក្រោកឡើងដើម្បីធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយ ។ មេធាវី អេនទ្រូ អ៊ីនូហ្ស៊ី បានបញ្ជាក់ថា គាត់ចង់បញ្ជាក់«ឲ្យច្បាស់» ទៅនឹងសំឡេងថតចម្លង ដែលក្រុមការពារក្តីរបស់ នួន ជា ជំទាស់ទៅនឹងតុលាការកាលពីព្រឹកមិញ ពេលសួរសំណួរទៅសាក្សី ឡុង នរិន្ទ អំពីរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ គាត ឈុន។ តាមគំនិតរបស់ភាគីការពារក្តី «ការជ្រៀតជ្រែកផ្នែកនយោបាយ គឺមិនពាក់ព័ន្ធគ្នាទេ» ។ មេធាវី អេនទ្រូ អ៊ីនូហ្ស៊ី បានថ្លែងអំណរគុណដល់មេធាវីការពារក្តីរបស់ជនជាប់ចោទផ្សេងទៀតដែលបាន«គាំទ្រ»កូនក្តីរបស់គាត់ពេញមួយថ្ងៃ ហើយគាត់បានសូមចេញលុយ«ផឹក»យប់នេះ ។ ភ្លាមនោះ ចៅក្រម ខាតវ៉ាយថ៍ បានឆ្លើយតបវិញថា ពាក្យសម្តីនេះមិនសមយកមកនិយាយនៅក្នុងបន្ទប់សវនាការទេ ហើយវាមិនសមរម្យ លោកស្រីចៅក្រមបានបន្ទោស ទៅមេធាវី អេនទ្រូ អ៊ីនូហ្ស៊ី ថា «នេះគឺជារឿងផ្សេង លោកអាចនិយាយរឿងនេះបានក្រៅតុលាការ» ។ សវនាការថ្ងៃនេះបញ្ចប់ ហើយសវនាការនឹងចាប់ផ្តើមឡើងវិញនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ។

**- ចប់ -**